ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តព្រៃវែង

សំណុំរឿងរដ្ឋប្បវេណី

លេខ : ១៩

ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១១

សាលក្រម

លេខ ១០ "ត" រ.វ

ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១១

# អាជ្ញាធរប្រជារាស្ត្រខ្មែរ

# សាលាដំបូងខេត្តព្រៃវែង

បញ្ចប់ការទាញហេតុផលផ្ទាល់មាត់ ថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០១១

និងប្រកាសសាលក្រមជាសាធារណៈនៅ ថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០១១

ចៅក្រមជំនុំជំរះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តព្រៃវែង

ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជី សាលាដំបូងខេត្តព្រៃវែង

ដើមចោទឈ្មោះ [redacted] សួន ភេទប្រុស អាយុ ៤៩ ឆ្នាំ ជាតិខ្មែរ របររកស៊ីគ្រូបង្រៀន មានទីលំនៅសព្វថ្ងៃ ភូមិត្រពាំងរុន ឃុំកន្សោមអក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ។

ចុងចម្លើយឈ្មោះ [redacted] ធន់ ភេទប្រុស អាយុ ៤៩ ឆ្នាំ ជាតិខ្មែរ របររកស៊ីគ្រូបង្រៀន មានទីលំនៅសព្វថ្ងៃ ភូមិកន្សោមអក ឃុំកន្សោមអក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង និងប្រពន្ធឈ្មោះ [redacted] ដានី របររកស៊ីគ្រូបង្រៀន មានទីលំនៅសព្វថ្ងៃ ភូមិកន្សោមអក ឃុំកន្សោមអក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ។

## អង្គហេតុ និងចំណុចវិវាទ

**១. ការទាមទាររបស់ដើមចោទ**

- **សុំទាមទារប្រាក់ជំពាក់ចំនួន ៨,១៥០,០០០៛ ( ប្រាំបីលានមួយសែនប្រាំម៉ឺនរៀល)**
- **សុំទាមទារសោហ៊ុយបង់ខាតចំនួន ២,០០០,០០០៛(ពីរលានរៀល)**

**២. អំពីដំណើររឿងក្តី**

កាលពីដំបូងឡើយចុងចម្លើយឈ្មោះ [redacted] ធន់ និងប្រពន្ធឈ្មោះ [redacted] ដានី បានទៅឱ្យដើមចោទឈ្មោះ [redacted] សួន ខ្ចីចងការប្រាក់របស់គេទោឱ្យខ្លួន រួមទាំងចូលរួមលេងតុងទីនជាមួយដើមចោទ រហូតដល់មានការជំពាក់ប្រាក់ដើមចោទ សរុបចំនួន៨,១៥០,០០០៛ ( ប្រាំបីលានមួយសែនប្រាំម៉ឺនរៀល) ។ លុះមកដល់ថ្ងៃទី១៣-១២-២០១០ ចុងចម្លើយ ក៏បានទៅធ្វើកិច្ចសន្យាព្រមព្រៀងទទួលស្គាល់ជំពាក់ប្រាក់ដើមចោទ ចំនួន៨,១៥០,០០០៛ ( ប្រាំបីលានមួយសែនប្រាំម៉ឺនរៀល) ប្រាកដមែន។ តែក្រោយពីមានការទទួលស្គាល់ថាមានការជំពាក់រួចហើយ ចុងចម្លើយនៅតែមិនព្រមសង ជាដដែល ។



១២៥

11/2

## ៣.ការអះអាងរបស់ភាគី :

### ក/ការអះអាងរបស់ដើមចោទ

ដើមចោទថា : កាលពីដំបូងឡើយឈ្មោះ [redacted] ធន់ និងប្រពន្ធឈ្មោះ [redacted] ដានី បានទៅឱ្យខ្លួន ខ្ចីចងការប្រាក់របស់គេទៅឱ្យគាត់ រួមទាំងចូលរួមលេងតុងទីនជាមួយខ្លួន រហូតដល់មានការជំពាក់ប្រាក់ខ្លួន សរុបមានចំនួន ៨,១៩០,០០០៛ (ប្រាំបីលានមួយសែនប្រាំម៉ឺនរៀល)។ លុះមកដល់ថ្ងៃទី១៣-១២-២០១០ ឈ្មោះ [redacted] ធន់ និងប្រពន្ធឈ្មោះ [redacted] ដានី ក៏បានទៅធ្វើកិច្ចសន្យាព្រមមព្រៀងទទួលស្គាល់ជំពាក់ប្រាក់ខ្លួនចំនួន៨,១៩០,០០០៛ (ប្រាំបីលានមួយសែនប្រាំម៉ឺនរៀល) ប្រាកដមែន។ តែក្រោយពីមានការទទួលស្គាល់ថាមានការជំពាក់រួចហើយ ឈ្មោះ [redacted] ធន់ និងប្រពន្ធឈ្មោះ [redacted] ដានី នៅតែមិនព្រមសងប្រាក់មកខ្លួនជាដដែល។ ក្នុងរឿងនេះខ្លួនសុំទាមទារជំងឺចិត្ត និងការខាតបងពេលវេលាចំនួន២,០០០,០០០៛ (ពីរលានរៀល)។ ដូច្នេះនៅក្នុងរឿងនេះខ្លួននៅតែទាមទារប្រាក់ដែលចុងចម្លើយជំពាក់ដដែល។

### ខ/ ការអះអាងរបស់ចុងចម្លើយ

ចុងចម្លើយថា: រូបខ្លួនឈ្មោះ [redacted] ធន់ និងប្រពន្ធឈ្មោះ [redacted] ដានី ពិតជាបានជំពាក់ប្រាក់ឈ្មោះ [redacted] សួន ចំនួន៨,១៩០,០០០៛ (ប្រាំបី លានមួយសែនប្រាំម៉ឺនរៀល) ប្រាកដមែន ។ តែប្រាក់នេះខ្លួនសុំសងទៅដើមចោទចំនួន ១៥០,០០០៛ (ដប់ប្រាំម៉ឺនរៀល) ក្នុងមួយខែ ដោយក្នុងរយៈពេល០២ខែសងម្តង។

## សំអាងហេតុ

ឆ្លងតាមការសាកសួរសោម៉ីភាគី និងការពិនិត្យភស្តុតាង តាមនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់រួចមក:

យល់ឃើញថា : ឈ្មោះ [redacted] ធន់ និងប្រពន្ធឈ្មោះ [redacted] ដានី បានធ្វើការប្តឹងទាស់ទៅនឹងសាលក្រមកំបាំងមុខរបស់ខ្លួនដោយសំណូមពរឱ្យតុលាការធ្វើការសម្រេចសេចក្តីសារជាថ្មីឡើងវិញដោយអះអាងថា នៅពេលដែលតុលាការធ្វើការសម្រេចសេចក្តីនោះ ខ្លួនមិនបានចូលខ្លួនមកមានមតិតវ៉ាជាមួយដើមបណ្តឹងនោះឡើយ។

យល់ឃើញថា : ឈ្មោះ [redacted] ធន់ និងប្រពន្ធឈ្មោះ [redacted] ដានី ពិតជាបានជំពាក់ប្រាក់ឈ្មោះ [redacted] សួន ចំនួន៨,១៩០,០០០៛ (ប្រាំបី លានមួយសែនប្រាំម៉ឺនរៀល) ប្រាកដមែន។

យល់ឃើញថា : ផ្អែកតាមកិច្ចសន្យា ចុះថ្ងៃទី១៣-១២-២០១០ចុងចម្លើយឈ្មោះ [redacted] ធន់ និងប្រពន្ធឈ្មោះ [redacted] ដានី បានទទួលស្គាល់ថាខ្លួន ពិតជាបានជំពាក់ប្រាក់ឈ្មោះ [redacted] សួន ចំនួន ៨,១៩០,០០០៛ (ប្រាំបីលានមួយសែនប្រាំម៉ឺនរៀល) ប្រាកដមែន។

យល់ឃើញថា: ការប្តឹងទាមទារប្រាក់ជំពាក់ចំនួន ៨,១៩០,០០០៛ (ប្រាំបី លានមួយសែនប្រាំម៉ឺនរៀល) របស់ដើមចោទ មានលក្ខណៈត្រឹមត្រូវតាមច្បាប់។

ចំពោះការសុំទាមទារសំណងជំងឺចិត្ត និងការខាតបង់ពេលវេលារបស់ដើមចោទ តុលាការយល់ឃើញថា គប្បីតុលាការលើកយកមកពិចារណា។

ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។



១២៦

Scanned with CamScanner

11/1

## សេចក្តីសម្រេចចុងក្រោយ

១- តំកល់សាលក្រមលេខ ០៨ "ផ" ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ២០១១ ទុកជាបានការទាំងមូល។

២- ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

សាលក្រមនេះឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ និងប្រកាសជាសាធារណៈនៅថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០១១ ចំពោះមុខភាគី បើកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

ចៅក្រមជំនុំជម្រះ

[redacted]



១២៧

Scanned with CamScanner